ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខៈ ០០១ សហវ

លិខិតចូល
ថ្ងៃទី ៣០ ខែ ... ឆ្នាំ 20...

# សារាចរណែនាំ
## ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគំរោងថវិកា
## ខេត្ត ក្រុងឆ្នាំ ២០០៨

យោងសារាចរណែនាំលេខ ០៤ សរណន ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាល ស្តីពីការ រៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨

យោងប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់ខេត្ត ក្រុង ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេស នៃការរៀបចំគំរោងថវិកាខេត្ត ក្រុង ឆ្នាំ ២០០៨ ដូចតទៅ ÷ គំរោងថវិកាខេត្ត ក្រុងសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ត្រូវរៀបចំទៅតាមទំរង់ និងមាតិកាថវិកា ដូចមានជូនភ្ជាប់ជាមួយ និងសារាចរណែនាំនេះ ។

## I. ការរៀបចំចំណូលថវិកា :

1. ការគិតគូរចំណូលចរន្តរបស់ថវិកាខេត្ត-ក្រុង អាស្រ័យទៅលើប្រភពនៃផលិតផល ឬផលទុន ដូចមានចែងក្នុងមាត្រា ១៧ ថ្មី នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលបានកែប្រែដោយមាត្រា ៦ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

ផ្អែកតាមប្រភពធនធានខាងលើនេះ អភិបាលខេត្ត-ក្រុង ត្រូវរៀបចំនូវគំរោងចំណូលថវិការបស់ខេត្ត-ក្រុង សាមីដូចតទៅ ÷

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
  + លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  + ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  + ប៉ាន់ស្មានលើការរីកចំរើនសេដ្ឋកិច្ចនៅពេលខាងមុខ
  + ការប្រែប្រួលដែលអាចកើតមានឡើង ឬត្រូវពិនិត្យពិចារណាលើអត្រា និងមូលដ្ឋានប្រមូលពន្ធ
  + ចំណូលដែលសង្ឃឹមថា បានមកពីការបង្កើតពន្ធថ្មី ( ករណីមានគោលនយោបាយថ្មី) ។

ទន្ទឹមនឹងនេះ ចំណូលមិនមែនសារពើពន្ធ ត្រូវបានគិតគូរទៅតាមកិច្ចការដែលនាំអោយមានផលទុន ដូចជាកិច្ចសន្យាជួល សេវាកម្ម ។ល ។ ចំណូលទាំងអស់នេះ ត្រូវផ្អែកលើមូលដ្ឋានតួលេខស្ថិតិសំរេចបាននៃឆ្នាំកន្លងមក និងការវិវឌ្ឍន៍នៃសេដ្ឋកិច្ច ។

ចំពោះនីតិវិធី គឺអភិបាលខេត្ត-ក្រុង ត្រូវអញ្ជើញមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សាខាពន្ធដារ និងមន្ទីរជំនាញ ដែលពាក់ព័ន្ធ ក្នុងការប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ សំរាប់ថវិកាខេត្ត-ក្រុង ដើម្បីមកចូលរួម ពិភាក្សាគិតគូររៀបចំជាគំរោងចំណូល ទៅតាមជំពូក គណនី អនុគណនីនៃតារាងឧបសម្ព័ន្ធទី១ ដែលជូនភ្ជាប់មក ជាមួយនេះ ។

2. ចំណូលផ្ទៃក្នុងជាមូលធនរបស់ថវិកាខេត្ត-ក្រុង ក្នុងករណីដែលមាន គឺត្រូវយកចិត្តទុកដាក់បញ្ចូលទៅក្នុង គំរោងចំណូល ។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់កត់ត្រាបញ្ចូលនូវចំណូលពីជំនួយមនុស្សធម៌ និងជំនួយពីបរទេស ដែលសប្បុរសជន អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា បានទៅទំនាក់ទំនងផ្ទាល់ជាមួយខេត្ត-ក្រុង រួចហើយនោះ ។

## II. ការរៀបចំចំណាយថវិកា :

3. ខេត្ត-ក្រុង ត្រូវរៀបចំនូវគំរោងចំណាយទៅតាមជំពូក គណនី អនុគណនីសំរាប់រាល់សកម្មភាពសេវា ទាំងអស់ ដោយកាត់បន្ថយមុខចំណាយណាដែលពុំចាំបាច់ ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ។របៀបគិតគូរនូវតំរូវ ការនានា គឺជាការកំណត់នូវមុខចំណាយនីមួយៗអោយច្បាស់លាស់ និងដោយផ្អែកទៅលើកត្តានានា ដែលទាក់ទង ផ្ទាល់ទៅនឹងមុខចំណាយនោះដូចជា តារាងបុគ្គលិក បញ្ជីបាន់ស្មានបរិមាណ តំលៃ សម្ភារៈ ឬសេវា..។ ចំពោះ សម្ភារៈបរិក្ខា ដែលប្រើប្រាស់ជាប្រចាំត្រូវគិតគូរដោយផ្អែក តាមតួលេខស្ថិតិគណនេយ្យថវិកាជាមធ្យមភាគ នៃ បណ្តាឆ្នាំកន្លងមក។ ចំណែកឯ សោហ៊ុយធ្វើដំណើរ ស្នាក់នៅ បេសកកម្ម ត្រូវផ្អែកលើរបបកំណត់ជាធរមាន (អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការកំណត់ប្រាក់របបបេសកកម្ម ក្នុង និងក្រៅប្រទេស) និង ប្រាក់ឈ្នួលផ្ទះ ទឹកភ្លើងរបស់អភិបាល អភិបាលរងគ្រប់ខេត្ត ក្រុងត្រូវគ្រោងក្នុងលក្ខណៈ កំរិតអប្បរមាដោយផ្អែក លើមូលដ្ឋានលទ្ធភាពនៃថវិកាខេត្ត-ក្រុង និងការកំណត់របស់អភិបាលខេត្ត-ក្រុង ។

គំរោងចំណាយទាំងអស់របស់ថវិកាខេត្ត-ក្រុង ត្រូវបានសរុបនៅក្នុងតារាងឧបសម្ព័ន្ធទី២ ដែលជូនភ្ជាប់មក ជាមួយនេះ ។

4. ជាទូទៅ សំណើចំណាយទាំងអស់ត្រូវតែមានការវិភាគ និងមានលិខិតយុត្តិការភ្ជាប់មកជាមួយតាមជំពូក គណនី អនុគណនី ដើម្បីបង្ហាញអោយឃើញថា ការគិតគូរចំណាយរបស់ខ្លួនមានភាពត្រឹមត្រូវ ហ្មត់ចត់ និងសម ហេតុផល ។ លិខិតយុត្តិការទាំងអស់នេះ នឹងធ្វើជាមូលដ្ឋាននៃការពិនិត្យពិភាក្សាថវិកា ។

## II.1. ការរៀបចំគំរោងចំណាយចរន្ត :

5. លិខិតយុត្តិការនៃចំណាយចរន្តមានគោលដៅសំខាន់ៗដូចតទៅ ÷

### ប្រភេទ ១ : មធ្យោបាយសេវា
### ជំពូក ៦២ និង ៦៤ សេវាខាងក្រៅផ្សេងៗ និងបន្ទុកបុគ្គលិក

6. ចំណាយសំរាប់បុគ្គលិកត្រូវតែគិតគូរអោយបានច្បាស់លាស់ ។ ចំណាយលើជំពូកនេះ ត្រូវបានចាត់ទុកជាចំណាយដែលមានអាទិភាពបំផុតក្នុងការរៀបចំគំរោងថវិកា ។ ចំណាយបន្ទុកបុគ្គលិកត្រូវគ្រោងដោយបង្កើន២០ % លើបៀវត្សមូលដ្ឋានទៅតាមតារាងប្រាក់បៀវត្សថ្មី នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០០៧ ។ ចំពោះចំនួនមន្ត្រីរាជការបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលនិងតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈនិងដែលមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណៈភាព ត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន។ ប្រសិនបើមានការតម្លើងឋានៈ ឬ មានមន្ត្រីថ្មី ត្រូវគ្រោងដោយឡែក។ ខេត្ត ក្រុង មិនត្រូវគិតអតិថរណានៅក្នុងចំណាយបៀវត្សនេះទេ ។

ក្នុងករណីដែលខេត្ត-ក្រុង ស្នើសុំបន្ថែមបុគ្គលិកអណ្តែត ភ្នាក់ងារជាប់កិច្ចសន្យា និងបុគ្គលិកប្រភេទ "គ", "ឃ" លើសពីក្របខ័ណ្ឌឥណទាន ដែលបានពិភាក្សារួចហើយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ ត្រូវស្នើសុំការធានាចំណាយថវិកាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតបន្ថែមអោយ ខេត្ត-ក្រុង ជ្រើសរើស និងប្រើប្រាស់ ។

ចំពោះគំរោង ចំណាយអំពីប្រាក់បំណាច់បុគ្គលិកអណ្តែត គំរោងចំណាយអំពីលាភការភ្នាក់ងារជាប់កិច្ចសន្យា និងកន្សោមអាទិភាព គឺចាំបាច់ត្រូវតែមានសេចក្តីសំរេចអនុញ្ញាតពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្របខ័ណ្ឌឥណទាន ដែលបានពិភាក្សារួចហើយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

#### ក- បុគ្គលិកដែលកំពុងមានក្នុងពេលបច្ចុប្បន្ន

7. ចំនួនបុគ្គលិកទាំងអស់ ដែលស្ថិតនៅក្រោមឱវាទខេត្ត-ក្រុង ត្រូវបូកសរុបនៅក្នុងតារាង៥ "ខ" ដែលបានភ្ជាប់ជូនមកជាមួយនេះ ។ សលាកប័ត្រនេះមានចែកជាច្រើនខ្ទង់ សំរាប់កត់ត្រានូវប្រភេទបុគ្គលិកទាំងអស់ដែលខេត្ត-ក្រុងមាន។

8. បុគ្គលិក មន្ត្រីរាជការ ដែលលំអិតទៅតាមអង្គភាពនីមួយៗហើយចំនួន នេះត្រូវតែផ្ទៀងផ្ទាត់ជាមួយ នឹងចំនួនដែលមាននៅក្នុងតារាងសរុបចំណាយ (តាមតារាងប្រព័ន្ធប្រាក់បៀវត្សរបស់ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលសាធារណៈ) ។

9. ខេត្ត-ក្រុង ត្រូវលំអិតចំនួនបុគ្គលិកទៅតាមស្រុក ខណ្ឌនីមួយៗ ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ។

**ខ- ការជ្រើសរើសបុគ្គលិកថ្មី**

10. អភិបាលខេត្ត-ក្រុង តែងតាំងបុគ្គលិកខេត្ត-ក្រុង ក្នុងក្របខណ្ឌនៃថវិការបស់ខេត្ត-ក្រុង ទៅតាមការកំណត់នៃលិខិតបទដ្ឋានដោយឡែកដែលមានជាធរមាន ក្រៅពីច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦/នស/៩៤. ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ហើយបុគ្គលិកទាំងនេះ ត្រូវគោរពតាមកាតព្វកិច្ចរបស់មុខងារសាធារណៈទាំងអស់ ។

## ជំពូក ៦០ និង ៦១ ការទិញ និងសេវាខាងក្រៅ

11. ជំពូក ៦០ និង ៦១ ប្រមូលផ្តុំរាល់ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ជួសជុលតូច និងចំណាយជាគុណប្រយោជន៍របស់ខេត្ត-ក្រុង ។ ឥណទានចំណាយក្នុងជំពូកនេះ ចែកចេញជាពីរផ្នែកសំខាន់ៗ÷

មួយផ្នែកជាឥណទានសំរាប់បំរើអោយកិច្ចប្រតិបត្តិការរដ្ឋបាលសុទ្ធសាធ ដែលចាំបាច់ត្រូវគិតគូរអោយបានហ្មត់ចត់ និងសន្សំសំចៃ ក្នុងឆ្នាំ ២០០៨ ផ្អែកលើគោលការណ៍រួមរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណាយសាធារណៈ ។ ឥណទានចំណាយផ្នែកនេះ គឺអនុញ្ញាតអោយគ្រោងក្នុងកំរិតប្រហាក់ប្រហែល នឹងឆ្នាំ២០០៧ តែប៉ុណ្ណោះ ។

មួយផ្នែកទៀតជាឥណទានសំរាប់បំរើដល់គុណប្រយោជន៍របស់ខេត្ត-ក្រុង ក្នុងការរៀបចំមូលដ្ឋានសំភារៈ នៃសេវាសាធារណៈ និងការអភិវឌ្ឍន៍របស់ខេត្ត-ក្រុង ។ ផ្អែកលើផែនការអភិវឌ្ឍន៍ខេត្ត-ក្រុង របស់ក្រសួងមហាផ្ទៃ ខេត្ត-ក្រុងនីមួយៗ ចាំបាច់ត្រូវរៀបចំតាមលំដាប់លំដោយ អាទិភាពនៃគំរោងចំណាយលំអិតជួសជុល និងកសាងថ្មី អំពីការងារជាគុណប្រយោជន៍របស់ខេត្ត-ក្រុង ដើម្បីដាក់គំរោងនេះឆ្លងការពិភាក្សា ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃក្នុងពេលធ្វើការពិភាក្សានៃគំរោងថវិកាប្រចាំឆ្នាំ ។

12. ជាទូទៅ ចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ការថែទាំ និងការជួសជុលតូច ត្រូវគិតគូរទៅតាមតំរូវការនៃកម្មវិធីសកម្មភាព ឬទៅតាមបទដ្ឋានសមស្រប ។ ម្យ៉ាងទៀត ខេត្ត-ក្រុងមិនត្រូវបំប៉ោងឥណទានដែលស្នើសុំសំរាប់ចំណាយប្រភេទនេះទេ ។ ឥណទានសំរាប់ចំណាយអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារៈ ការិយាល័យ ប្រេងឥន្ធនៈ ត្រូវកំណត់អោយបានត្រឹមត្រូវ និងគ្រប់គ្រងយ៉ាងម៉ឹងម៉ាត់ ដើម្បីសន្សំសំចៃលើចំណាយប្រភេទនេះ ជាពិសេសឥណទានសំរាប់ចំណាយទូរស័ព្ទ អគ្គិសនី ទឹក ខេត្ត-ក្រុងត្រូវគ្រោងអោយបានគ្រប់គ្រាន់សំរាប់តំរូវការក្នុងឆ្នាំ និងការសងបំណុល ។ ក្នុងករណីដែលខេត្ត-ក្រុង គ្រោងមិនបានគ្រប់គ្រាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើនិយ័តភាពឥណទានផ្ទៃក្នុងជំពូកថវិការបស់ខេត្ត-ក្រុង និងដាក់កម្មវិធីចំណាយសំរាប់ទូទាត់ជូនខេត្ត-ក្រុង ដោយស្វ័យប្រវត្តិ ។

13. ចំពោះឥណទានសំរាប់ចំណាយជាគុណប្រយោជន៍ ខេត្ត ក្រុង ខេត្ត ក្រុងត្រូវគ្រោងឥណទានតាមការងារនីមួយៗ (បំភ្លឺសាធារណៈ ប្រមូលសំរាម អនាម័យ សន្តិសុខ ប្រឆាំងអគ្គិភ័យ ការផ្គត់ផ្គង់ទឹក...) និងតាមការដ្ឋាននីមួយៗ

(ផ្លូវថ្នល់ ស្ពាន សួនច្បារ លូទឹក ប្រឡាយ...) ដោយមានបញ្ជាក់អំពីបញ្ជីប៉ាន់តម្លៃ និងទីតាំងច្បាស់លាស់សំរាប់យកមកពិភាក្សា សំរេចជាមួយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងពេលតែមួយនៃការពិភាក្សាថវិកាប្រចាំឆ្នាំ ។ ដោយឡែកចំពោះសំណង់ថ្មីទាំងស្រុង (បើមាន) ត្រូវលើកគំរោង និងចុះទៅតាមគណនី និងអនុគណនី ត្រង់ជំពូក ២០ (បើជាអចលកម្មអរូបីយ) និងត្រង់ជំពូក ២៧ (បើជាអចលកម្មរូបីយ) ។

## ជំពូក៦៥ : ការឧបត្ថម្ភធន និងជំនួយ

14. ចំណាយក្នុងជំពូកនេះ សំរាប់ការឧបត្ថម្ភអោយអង្គភាពសាធារណៈរដ្ឋបាល ដែលខេត្ត-ក្រុងបង្កើតឡើង ហើយកំរៃសាធារណៈ ដែលទទួលបានពុំអាចរ៉ាប់រងបានរាល់ការចំណាយចាំបាច់ ។

## ប្រភេទ ៣ : ចំណាយអន្តរាគមន៍សាធារណៈ

15. ចំណាយប្រភេទនេះ ត្រូវចែងលំអិតអោយបានច្បាស់លាស់ នូវគោលដៅដែលត្រូវសំរេច។ ត្រូវពិនិត្យជ្រើសរើសចំណាយប្រភេទនេះអោយបានហ្មត់ចត់ ដោយផ្អែកលើលក្ខណៈសម្បត្តិនៃអ្នកដែលទទួលផល និងចំនួនទឹកប្រាក់ដែលត្រូវពិនិត្យផ្តល់ជូន ។

## ប្រភេទ ៤ : ចំណាយផ្សេងៗ

16. ចំណាយប្រភេទនេះ គឺសំរាប់កាតព្វកិច្ចពន្ធ អាករ (លតាប័ត្រ.....) និងចំណាយផ្សេងៗ ទៀតតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ប្រភេទ ៦ : ចំណាយមិនបានគ្រោងទុក

17. ចំណាយប្រភេទនេះ គឺជាការគិតគូរគ្រោងបំរុងសំរាប់ចំណាយចៃដន្យ ដែលអាចកើតមានជាយថាហេតុនៅក្នុងឆ្នាំអនុវត្ត។ សំរាប់ឆ្នាំថវិកា ២០០៨ ប្រភេទឥណទាន គឺអនុញ្ញាតអោយគ្រោងចំនួន ៣ទៅ ៥ភាគរយ ហើយខ្ទង់ចំណាយនេះ ពេលអនុវត្តត្រូវស្នើសុំធ្វើនិយ័តភាពទៅបំពេញអោយជំពូកដទៃទៀត ដែលតំរូវការចំណាយចៃដន្យកើតមានឡើងជាយថាហេតុ ។

## II.2. ចំណាយជាមូលធន :

## ប្រភេទ ១ : អចលកម្ម

18. ចំណាយជាមូលធន គឺជាចំណាយសំរាប់ធ្វើហិរញ្ញប្បទានចំពោះគំរោងវិនិយោគ ដែលមានការព្រមព្រៀងគ្នាជាមុន និងសំដៅធ្វើអោយសំរេចតាមគោលដៅដែលបានដាក់ចេញ ។

19. គំរោងវិនិយោគរបស់ខេត្ត ក្រុងដែលអាចគ្រោងបានក្នុងករណីដែលខេត្ត ក្រុងបានទទួលគោលការណ៍អនុញ្ញាត ជាផ្លូវការ អោយគ្រប់គ្រងហិរញ្ញប្បទានដោយផ្ទាល់ ។

- ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសដោយថវិកាខេត្ត-ក្រុង អាចគ្រោងបានក្នុងករណីដែលខេត្ត-ក្រុងមានអតិរេកចរន្ត ឬ មានចំណូលជាមូលធនផ្ទៃក្នុង ខេត្ត-ក្រុងផ្ទាល់ ។

- ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ត្រូវផ្អែកលើកម្មវិធីជំនួយ ឬគំរោងការដែលអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ឬម្ចាស់ជំនួយទ្វេភាគីបានទៅទំនាក់ទំនងផ្ទាល់ជាមួយខេត្ត-ក្រុង ដើម្បីកត់ត្រាចូលទៅក្នុងគំរោងថវិការបស់ខេត្ត-ក្រុង ។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់ផងដែរ ក្នុងការកត់ត្រារាល់ចំណាយថវិកាបដិភាគជាប្រាក់រៀល ដែលត្រូវអនុវត្តជាមួយគំរោង ដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ។

20. ចំណាយនេះ ជាចំណាយកសាងថ្មីដែលមានទំហំទឹកប្រាក់ច្រើន ដូចជា ដីធ្លី អាគារ រៀបចំតុបតែងអាគារ និងសំណង់ផ្សេងៗទៀត ។

## III. សរុបគំរោងចំណូល ចំណាយ :

21. ឆ្នាំ ២០០៨ គឺជាឆ្នាំទី ៣ នៃការបន្តអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និងជាឆ្នាំទី ៤ នៃការបន្ត អនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** របស់រាជរដ្ឋាភិបាល ជាពិសេស ការបន្តរក្សាអោយបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យមពី ៦ ទៅ ៧ ភាគរយប្រកបដោយចីរភាព និងបន្តរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគន្លឹះ និងចាំបាច់បំផុតក្នុងការឈានទៅសំរេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ **ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន** ។ ទន្ទឹមនឹងនេះ វាក៏ជាឆ្នាំដែលត្រូវបន្តជំរុញការអនុវត្តន៍កម្មវិធីកែទំរង់ស៊ីជំរៅលើគ្រប់វិស័យ ដូចជា ការកែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការកែទំរង់រដ្ឋបាលសាធារណៈ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទំរង់កងកម្លាំងប្រដាប់អាវុធ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងជាពិសេសគឺជាឆ្នាំដែលត្រូវរៀបចំការបោះឆ្នោតសកលលើកទី ៤ ដើម្បីបន្តពង្រឹងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។

គំរោងចំណូល ចំណាយថវិការបស់ខេត្ត-ក្រុងនីមួយៗដែលបានពិតគូរ រួមមានទាំងការធានាចំណាយដែលមិនទាន់បានធ្វើការទូទាត់ និងចំណូលដែលមិនទាន់បានប្រមូលអស់នៃការគ្រប់គ្រងក្នុងឆ្នាំមុនៗផង ។ គំរោងចំណូលចំណាយនេះ ត្រូវរៀបចំអោយមានតុល្យភាពពិតប្រាកដ ដើម្បីរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។ក្នុងឆ្នាំ ២០០៨ នេះគ្រប់ខេត្ត ក្រុងត្រូវគ្រោងចំណាយចរន្តដែលមានលក្ខណៈជាចំណាយរដ្ឋបាលសុទ្ធសាធក្នុងកំរិតប្រហាក់ប្រហែលនឹងថវិកាដែលបានអនុម័តក្នុងឆ្នាំ ២០០៧ ។

22. ចំពោះគំរោងចំណាយចរន្ត ខេត្ត-ក្រុងត្រូវភ្ជាប់មកជាមួយនូវគំរោងបែងចែកលំអិត តាមស្រុកនីមួយៗ និងបណ្តាអង្គភាពចំណុះដែលមានទ្រង់ទ្រាយធំ ។

23. ដោយឡែកនៅឆ្នាំ ២០០៨ ខាងមុខនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តអនុវត្តកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ការឈានទៅសំរេចអោយបាននូវគោលដៅជំហានទី ១ គឺការធានាភាពជឿទុកចិត្តបាននៃថវិកា តាមរយៈការបន្តជំរុញការកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបង្កើនភាពគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា ដើម្បីធានាអោយការបើកផ្តល់ថវិកាបានទាន់ពេលវេលា និងការកសាងក្របខ័ណ្ឌគោលនយោបាយចំណូលដើម្បីរក្សាស្ថេរភាព និងនិរន្តរភាពចំណូល ។ ទន្ទឹមនឹងនេះ បន្តជំរុញការរៀបចំផែនការសកម្មភាព និងបន្តអនុវត្តនូវបណ្តាសកម្មភាពការងារសំរាប់ត្រៀមឈានទៅជំហានទី ២ និងទី ៣ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ និងការពង្រឹងការឆ្លើយតបនៃថវិកាទៅនឹងគោលនយោបាយ ដែលរួមមាន ការបន្តពង្រឹង និងកែលំអរការអនុវត្តនីប្លង់គណនេយ្យនិងមាតិកាថវិកាថ្មី ការបន្តពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី និងការបន្តជំរុញការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីអោយស្របទៅនឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្មី ដែលបាន និងកំពុងកសាង និងដាក់អោយអនុវត្តដោយផ្នែកៗ និងជាបណ្តើរៗ ក្រោមកម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ។

24. បន្តជម្រុញអនុវត្តកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ពិសេស ធានាពង្រឹងសមត្ថភាពរដ្ឋបាលបច្ចេកទេស និង ហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាឃុំ សង្កាត់ សំរាប់ការអភិវឌ្ឍន៍មូលដ្ឋាន និងពង្រីកមូលដ្ឋាននៃការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិសហមជ្ឈការ ពិសេសគឺដើម្បីបំរើអោយគោលការណ៍ "រដ្ឋបាលឯកភាព" ដូចមានកំណត់នៅក្នុងឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ។ ក្នុងកម្មវិធីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំ និងអនុវត្តផែនការបង្កើនប្រសិទ្ធភាពនៃការផ្ទេរ និងការផ្តល់ថវិកាជូនមូលនិធិឃុំ សង្កាត់ រួមមានទាំងលទ្ធភាពនៃការពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារផងដែរ ។ លើសពីនេះទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តសិក្សាដើម្បីដាក់អោយអនុវត្តសាកល្បងនូវការប្រមូលចំណូលផ្ទាល់ដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

25. បង្កើនមូលនិធិថវិកាឃុំ សង្កាត់ ឆ្នាំ ២០០៨ ដល់ ២,៧% នៃចំណូលចរន្តថវិកាជាតិឆ្នាំ ២០០៧ ដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ស្របតាមគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ ។

26. ពេលទទួលបានសារាចរណែនាំ ខេត្ត ក្រុង ត្រូវរៀបចំជាបន្ទាន់នូវគំរោងចំណូល ចំណាយថវិការបស់ខ្លួនសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ទៅតាមឧបសម្ព័ន្ធតារាងគំរូ ( ឧបសម្ព័ន្ធទី ១ ឧបសម្ព័ន្ធទី ២ និងតារាងលេខ ១ ដល់លេខ៧) ដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើរមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន) ចំនួនពីរច្បាប់ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៧ ដើម្បីមានពេលវេលាគ្រប់គ្រាន់សំរាប់ពិភាក្សាគិតជំនាញ និងបូកសរុបសំរាប់ពិភាក្សាចាប់ពីថ្ងៃទី ០១ ដល់ ៣១ ខែ សីហា ឆ្នាំ ២០០៧ ។ តួលេខគំរោងចំណូល ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1.2.3) ហើយឯកតាទាបបំផុតគិតត្រឹម 0.1 លានរៀល ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់យ៉ាងមុតមាំថា អភិបាលខេត្ត-ក្រុងទាំងអស់នឹងខិតខំយកចិត្តទុកដាក់ចាត់ចែងអនុវត្តតាមខ្លឹមសារនៃសារាចរនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៧

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  (ដើម្បីជូនជ្រាប)
- គ្រប់សាលាខេត្ត-ក្រុង
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត-ក្រុង
  (ដើម្បីមុខការ)
- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

ឧបសម្ព័ន្ធទី១ ៕

# ការគ្រប់គ្រងឆ្នាំ ២០០៨

# តារាងសរុបចំណូលថវិការបស់ខេត្ត ក្រុង

ឯកតា: លានរៀល

| ជំពូក | គណនី | គណនី | ការរាយមុខចំណូល (តាមមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០០៧ | | | គំរោងឆ្នាំ ២០០៨ |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ដើមឆ្នាំ | អនុវត្តឆមាសទី១ | ប៉ាន់ស្មានឆ្នាំ | |
| | | | | | | | |

ថ្ងៃទី..............ខែ..............ឆ្នាំ ២០០៧

អ្នកធ្វើតារាង

ថ្ងៃទី..............ខែ.............ឆ្នាំ ២០០៧

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ.............ឆ្នាំ ២០០៧

ហត្ថលេខា និង ត្រាអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

ឧបសម្ព័ន្ធទី២

# ការគ្រប់គ្រងឆ្នាំ ២០០៨

## តារាងសរុបចំណាយថវិការបស់ខេត្ត ក្រុង

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ការរាយមុខចំណាយ (តាមមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០០៧ | | | គំរោងឆ្នាំ ២០០៨ |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ដើមឆ្នាំ | អនុវត្តឆមាសទី១ | ប៉ាន់ស្មានឆ្នាំ | |
| | | | | | | | |

ថ្ងៃទី.............ខែ.............ឆ្នាំ ២០០៧

អ្នកធ្វើតារាង

ថ្ងៃទី..............ខែ ................ ឆ្នាំ ២០០៧

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ.............ឆ្នាំ ២០០៧

ហត្ថលេខា និង ត្រាអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

# គំរោងថវិកាឆ្នាំ ២០០៨

## គំរោងចំណាយលើការផលិត (ជំពូក ៦០)

តារាង ១

ឯកតា: លានរៀល

| ជំពូក គណនី អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧ | | | គំរោងថវិកាឆ្នាំ ២០០៨ | | |
|---|---|---|---|---|---|---|---|---|---|
| | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

ថ្ងៃទី.........ខែ............ឆ្នាំ ២០០៧
អ្នកធ្វើតារាង

ថ្ងៃទី............ខែ ................ ឆ្នាំ ២០០៧
ហត្ថលេខា និង ត្រាប្រធានមន្ទីរ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ............ឆ្នាំ ២០០៧
បានឃើញ និងឯកភាព
ហត្ថលេខា និង ត្រាអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

# គំរោងថវិកាឆ្នាំ ២០០៨

## គំរោងចំណាយលើសេវាខាងក្រៅ (ជំពូក ៦១) (គុណប្រយោជន៍ខេត្ត ក្រុង)

តារាង ២

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧ | | | គំរោងថវិកាឆ្នាំ ២០០៨ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាទៅឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាទៅឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

ថ្ងៃទី............ខែ............ឆ្នាំ ២០០៧

អ្នកធ្វើតារាង

ថ្ងៃទី.............ខែ ...............ឆ្នាំ ២០០៧

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ............ឆ្នាំ ២០០៧

បានឃើញ និងឯកភាព

ហត្ថលេខា និង ត្រាអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

# គំរោងថវិកាឆ្នាំ ២០០៨

## គំរោងចំណាយលើសេវាក្រៅផ្សេងៗ (ជំពូក ៦២)

តារាង ៣

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧ | | | គំរោងថវិកាឆ្នាំ ២០០៨ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |

ថ្ងៃទី........... ខែ............ឆ្នាំ ២០០៧

អ្នកធ្វើតារាង

ថ្ងៃទី............. ខែ ............... ឆ្នាំ ២០០៧

មន្ត្រីលេខា និង ប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី........... ខែ............ឆ្នាំ ២០០៧

បានឃើញ និងឯកភាព

មន្ត្រីលេខា និង ក្រុមអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

## គំរោងថវិកាឆ្នាំ ២០០៨

## គំរោងចំណាយលើពន្ធ និង អាករ (ជំពូក ៦៣)

តារាង ៤

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧ | | | គំរោងថវិកាឆ្នាំ ២០០៨ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបញ្ជាក់ការគណនាទៅឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបញ្ជាក់ការគណនាទៅឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |

ថ្ងៃទី............ខែ..... ........ឆ្នាំ ២០០៧
អ្នកធ្វើតារាង

ថ្ងៃទី............ខែ ................ ឆ្នាំ ២០០៧
ហត្ថលេខា និង ត្រាប្រធានមន្ទីរ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ.............ឆ្នាំ ២០០៧
បានឃើញ និងឯកភាព
ហត្ថលេខា និង ត្រាអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

# គំរោងថវិកាឆ្នាំ ២០០៨

## គំរោងចំណាយលើបន្ទុកបុគ្គលិក (ជំពូក ៦៤)

តារាង៥ "ក"

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧ | | | គំរោងថវិកាឆ្នាំ ២០០៨ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

ថ្ងៃទី............ខែ............ឆ្នាំ ២០០៧

អ្នកធ្វើតារាង

ថ្ងៃទី............ខែ ............... ឆ្នាំ ២០០៧

មន្ត្រីលេខា និង ប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី...........ខែ............ឆ្នាំ ២០០៧

បានឃើញ និងឯកភាព

មន្ត្រីលេខា និង ប្រធានអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តារាង៥ "ខ"

ខេត្ត ក្រុង:...........

## ការគ្រប់គ្រងឆ្នាំ ២០០៧
## តារាងសរុបនៃបុគ្គលិក, បៀវត្ស និង ប្រាក់បំណាច់

| អង្គភាព | បៀវត្សសរុប | ចំនួនបុគ្គលិកសរុប | ប្រភេទបុគ្គលិកដែលមានសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ | | | | | បុគ្គលិកអណ្តែត | បុគ្គលិកជាប់កិច្ចសន្យា |
|---|---|---|---|---|---|---|---|---|---|
| | | | បុគ្គ.អចិន្ត្រៃយ៍សរុប | ប្រភេទ "ក" | ប្រភេទ "ខ" | ប្រភេទ "គ" | ប្រភេទ "ឃ" | | |
| សរុប | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| ............... | | | | | | | | | |
| ............... | | | | | | | | | |
| ............... | | | | | | | | | |
| ............... | | | | | | | | | |
| ............... | | | | | | | | | |
| ............... | | | | | | | | | |

ថ្ងៃទី.............ខែ.............ឆ្នាំ ២០០៧
បានឃើញ និងឯកភាព
អគ្គលេខា និង ក្រុមអភិបាលខេត្ត

ថ្ងៃទី...............ខែ ................ ឆ្នាំ ២០០៧
អគ្គលេខា និង ក្រុមប្រធានមន្ទីរ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី.............ខែ.............ឆ្នាំ ២០០៧
អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

# គំរោងថវិកាឆ្នាំ ២០០៨

## គំរោងចំណាយលើឧបត្ថម្ភធន និងជំនួយសង្គម (ជំពូក ៦៥)

តារាង ៦

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧ | | | គំរោងថវិកាឆ្នាំ ២០០៨ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |

ថ្ងៃទី............ខែ.............ឆ្នាំ ២០០៧

អ្នកធ្វើតារាង

ថ្ងៃទី.............ខែ ................ ឆ្នាំ ២០០៧

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ............ឆ្នាំ ២០០៧

បានឃើញ និងឯកភាព

ហត្ថលេខា និង ត្រាអភិបាលខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

# គំរោងថវិកាឆ្នាំ ២០០៨

## អចលកម្មអរូបី និងអចលកម្មរូបី (ជំពូក ២០ និង ២១)

តារាង ៧

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៧ | | | គំរោងថវិកាឆ្នាំ ២០០៨ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |

ថ្ងៃទី............ខែ............ ឆ្នាំ ២០០៧

អ្នកធ្វើតារាង

ថ្ងៃទី..............ខែ ............... ឆ្នាំ ២០០៧

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី...........ខែ............ឆ្នាំ ២០០៧

បានឃើញ និងឯកភាព

ហត្ថលេខា និង ត្រាអភិបាលខេត្ត